**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៥០ អនក្រ.បក

# អនុក្រឹត្យ

## ស្ដីពី

## ការកំណត់តំបន់សហគមន៍ លើផ្ទៃដីទំហំ១ ១៥៤(មួយពាន់មួយរយហាសិបបួន) ហិកតា ស្ថិតនៅក្នុងឧទ្យានជាតិបុទុមសាគរ ភូមិសាស្ត្រឃុំតានូន ស្រុកបូទុមសាគរ ខេត្តកោះកុង

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្ដីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីកិច្ចការពារបរិស្ថាននិងការគ្រប់គ្រងធនធានធម្មជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០៨/០០៧ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីតំបន់ការពារធម្មជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីភូមិបាល
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្ដីពីការកំណត់តំបន់ការពារធម្មជាតិ
- បានឃើញអនុក្រឹត្យលេខ២៣៤ អនក្រ.បក ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០២១ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន
- បានឃើញអនុក្រឹត្យលេខ១៩១ អនក្រ.បក ចុះថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០២១ ស្ដីពីការធ្វើអនុប្បយោគផ្ទៃដីទំហំ១ ១៥៤(មួយពាន់មួយរយហាសិបបួន)ហិកតា ស្ថិតនៅក្នុងឧទ្យានជាតិបុទុមសាគរ ភូមិសាស្ត្រឃុំតានូន ស្រុកបូទុមសាគរ ខេត្តកោះកុង ជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ ដើម្បីធ្វើការដោះស្រាយជូនប្រជាពលរដ្ឋរងផលប៉ះពាល់ជាមួយក្រុមហ៊ុនយូញៀន ឌីវេឡុបមេន គ្រុប ខូ អិលធីឌី និងត្រៀមបម្រុងទុកសម្រាប់អនុវត្តកម្មវិធីសម្បទានដីសង្គមកិច្ច
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងបរិស្ថាន

## សម្រេច

**មាត្រា១ .-**

ត្រូវបានកំណត់ជាតំបន់សហគមន៍ លើផ្ទៃដីទំហំ១ ១៥៤(មួយពាន់មួយរយហាសិបបួន)ហិកតា ស្ថិតនៅក្នុងឧទ្យានជាតិបុទុមសាគរ ភូមិសាស្ត្រឃុំតានូន ស្រុកបូទុមសាគរ ខេត្តកោះកុង សម្រាប់ដោះស្រាយជូនប្រជាពលរដ្ឋរងផលប៉ះពាល់ជាមួយក្រុមហ៊ុន យូញៀន ឌីវេឡុបមេន គ្រុប ខូ អិលធីឌី (Union Development Group Co,. Ltd.) និងត្រៀមបម្រុងទុកសម្រាប់អនុវត្តកម្មវិធីសម្បទានដីសង្គមកិច្ចជូនប្រជាពលរដ្ឋក្រីក្រដែលគ្មានដីធ្លីសម្រាប់សាងសង់លំនៅឋាននិងធ្វើកសិកម្មជាលក្ខណៈគ្រួសារ ព្រមទាំងសម្រាប់រៀបចំហេដ្ឋារចនាសម្ព័ន្ធសាធារណៈ ដូចមានផែនទីនិងនិយាមកាភ្ជាប់ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

**មាត្រា២ .-**

តំបន់សហគមន៍នៃឧទ្យានជាតិបុទុមសាគរ ស្ថិតនៅភូមិសាស្ត្រឃុំតានូន ស្រុកបូទុមសាគរ ខេត្តកោះកុង ត្រូវបានកំណត់ជាតំបន់គ្រប់គ្រងស្ថិតក្រោមសមត្ថកិច្ចក្រសួងបរិស្ថាន សម្រាប់បម្រើឱ្យការអភិវឌ្ឍសេដ្ឋកិច្ចសង្គមកិច្ចរបស់ប្រជាពលរដ្ឋមូលដ្ឋាន។ រាល់ការចេញប័ណ្ណដីធ្លីឬការអនុញ្ញាតឱ្យប្រើប្រាស់ដីធ្លីនៅក្នុងតំបន់នេះ ត្រូវមានការបញ្ជាក់យល់ព្រមជាមុនពីក្រសួងបរិស្ថានដោយអនុលោមតាមច្បាប់ភូមិបាល។

**មាត្រា៣ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៤ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តកោះកុង ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃសុក្រ ៩ កើត ខែ ផល្គុន ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ មីនា ឆ្នាំ២០២២

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីសូមហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងបរិស្ថាន**

**សាយ សំអាល់**

**កន្លែងទទួល** :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៤
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ




| Id | X | Y |
|---|---|---|
| 1 | 312670.119 | 1217460.158 |
| 2 | 318756.247 | 1217399.828 |
| 3 | 318689.989 | 1214096.284 |
| 4 | 317173.000 | 1214902.000 |
| 5 | 316818.000 | 1214424.000 |
| 6 | 316768.590 | 1214477.176 |
| 7 | 316005.000 | 1215299.000 |
| 8 | 316126.000 | 1215460.000 |
| 9 | 315526.000 | 1215564.000 |
| 10 | 315019.000 | 1215796.000 |
| 11 | 314404.000 | 1216335.000 |
| 12 | 313928.000 | 1216221.000 |